# ច្បាប់ប្រព្រឹត្តកិរិយា នៅការដ្ឋាន

ពលកម្មដោយបង្ខំ ។ មិនត្រូវមានការប្រើឲ្យធ្វើការងារដោយបង្ខំឡើយ ទោះបីជាក្នុងទំរង់នៃការឃុំឃាំងឲ្យធ្វើការងារ ឬកិច្ចសន្យាធ្វើការងារដោយមានលក្ខខ័ណ្ឌ ឬក៏ឲ្យធ្វើការងារដោយមានធានាអះអាង អ្វីមួយសោះឡើយ ។

ពលកម្មកូនក្មេង ។ មនុស្សណាដែលមានអាយុតិចជាង ១៥ ឆ្នាំ (ឬ ១៤ ឆ្នាំ នៅទីណាច្បាប់ប្រទេសនៃផលិតផល[១]អនុញ្ញាត) ឬក៏មានអាយុក្មេងជាង ដែលជាចាំបាច់ត្រូវតែបញ្ចប់ការសិក្សា នៅក្នុងប្រទេសនៃផលិតផល ជាទីដែលថាអាយុត្រូវធ្វើការគឺខ្ពស់ជាង ១៥ ឆ្នាំ នឹងមិនត្រូវបានជួលឲ្យធ្វើការឡើយ ។

ការយាយី និងការធ្វើទុក្ខទោស ។ កូនឈ្នួលម្នាក់ៗត្រូវតែបានប្រព្រឹត្តដោយគោរព និងដោយសេចក្តីថ្លៃថ្នូរ ។ គ្មានកូនឈ្នួលណាម្នាក់នឹងត្រូវឋិតក្នុងការយាយី ឬការធ្វើទុក្ខទោសចំពោះរូបកាយ ការសេពសន្ថវៈ ខាងផ្លូវចិត្ត ឬខាងពាក្យសំដី អ្វីសោះឡើយ ។

ការមិនប្រកាន់ ។ គ្មានមនុស្សណានឹងត្រូវបានប្រកាន់នៅក្នុងការងារទេ គឺរាប់ទាំងការជួលធ្វើការ ប្រាក់ខែ អត្ថប្រយោជន៍ ការឡើងមុខដំណែង ការដាក់វិន័យ ការបញ្ឈប់ឲ្យធ្វើការ ឬការលាលែងធ្វើការ ដោយសំអាងលើភេទ ជាតិសាសន៍ សាសនា អាយុ ភាពពិការ បែបសេពសន្ថវៈ សញ្ជាតិ មតិនយោបាយ ឬវណ្ណៈសង្គម ឬក៏ដើមកំណើតជាតិពន្ធ សោះឡើយ ។

សុខភាព និងសន្តិសុខ ។ កូនឈ្នួលទាំងឡាយត្រូវផ្តល់នូវភាពសន្តិសុខ និងបរិយាកាសធ្វើការដោយមានសុខភាពល្អ ដើម្បីបង្ការការគ្រោះថ្នាក់ និងការពារកុំឲ្យមានរបួសចំពោះសុខភាព ដែលកើតចេញពីការងារ ឬទាក់ទងនឹងការងារ ឬកើតឡើងនៅក្នុងកំឡុងពេលធ្វើការ ឬក៏ជាលទ្ធផលនៃដំណើរការរបស់កូនឈ្នួលម្នាក់នៅស្ថាប័ន ។

សេរីភាពនៃសមាគម និងការចរចាកិច្ចព្រមព្រៀង ។ កូនឈ្នួលទាំងឡាយត្រូវទទួលស្គាល់ និងគោរពសិទ្ធិរបស់កូនឈ្នួលទាំងពួងចំពោះសេរីភាពនៃសមាគម និងការចរចាកិច្ចព្រមព្រៀង ។

ថ្លៃឈ្នួល និងអត្ថប្រយោជន៍ ។ កូនឈ្នួលទាំងឡាយទទួលស្គាល់ថា ថ្លៃឈ្នួលគឺជាធនត្រូវការចាំបាច់ សំរាប់ដំរូវសេចក្តីត្រូវការជាគោលរបស់កូនឈ្នួលទាំងពួង ។ ថៅកែត្រូវបើកប្រាក់ឲ្យកូនឈ្នួល តាមចំនួនទាបបំផុត គឺយ៉ាងហោចណាស់តាមថ្លៃឈ្នួលអប្បរិមាដែលច្បាប់នៅតាមតំបន់បានដំរូវ ឬក៏តាមថ្លៃឈ្នួលទូទៅនៃឧស្សាហកម្ម តាមការណាមួយដែលខ្ពស់ជាង ទាំងផ្តល់អត្ថប្រយោជន៍ដែលការច្បាប់បានអាណត្តិ(បង្គាប់) ។

ពេលម៉ោងធ្វើការ ។ វៀរលែងតែក្នុងកាលៈទេសៈមុខរបរប្លែកពីធម្មតា នោះកូនឈ្នួលទាំងឡាយនឹង (១) មិនដំរូវឲ្យធ្វើការហួសពី (ក) ៤៨ ម៉ោង ក្នុងមួយអាទិត្យ និងធ្វើការលើស ១២ ម៉ោង ឬ (ខ) តាមកំរិតធម្មតា និងការធ្វើលើសម៉ោងដែលច្បាប់ប្រទេសនៃផលិតផលបានអនុញ្ញាត ឬក៏នៅទីណាដែលប្រទេសនោះមិនកំរិតម៉ោងធ្វើការ ជាម៉ោងធ្វើការធម្មតាក្នុងមួយអាទិត្យ ក្នុងប្រទេសនោះ បូកនឹងការធ្វើលើស ១២ ម៉ោង ហើយ (២) មានសិទ្ធិសំរាកយ៉ាងហោចណាស់មួយថ្ងៃ ក្នុងរយៈពេលរាល់ប្រាំពីរថ្ងៃ ។

ការសងប្រាក់ធ្វើការលើសម៉ោង ។ ជាបន្ថែមទៅលើការសងប្រាក់ចំពោះម៉ោងធ្វើការធម្មតារបស់គេ នោះកូនឈ្នួលទាំងឡាយនឹងត្រូវបានសងប្រាក់ថ្លៃធ្វើការលើសម៉ោង តាមដំឡៃបន្ថែមនោះ ដូចការច្បាប់នៅប្រទេសនៃផលិតផលបានដំរូវ ឬក៏បើនៅប្រទេសនោះពុំមានច្បាប់យ៉ាងដូច្នោះទេ ត្រូវសងតាមដំឡៃយ៉ាងហោចណាស់ស្មើនឹងដំឡៃប្រាក់ម៉ោងធម្មតារបស់គេ ។

* * *

[១] សំអាងទៅលើច្បាប់នៅតាមតំបន់ទាំងអស់ នៅសព្វច្បាប់នេះ នឹងរាប់ទាំងការប្រតិបត្តិបញ្ញត្តិនានា ដោយស្របតាមច្បាប់នៅក្នុងតំបន់ដែលអាចអនុវត្តបាន ។